**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
លេខ. ........................

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំប្រតិភូយោធាជាន់ខ្ពស់ក្រសួងការពារជាតិ ចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM Retreat) និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក លើកទី៦ (6th ADMM-Plus) ដែលនឹងប្រព្រឹត្តទៅពី **ថ្ងៃទី១៦-១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។**

នៅក្នុងកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការពារជាតិអាស៊ាន(ADMM Retreat) សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងធ្វើការផ្លាស់ប្តូរទស្សនៈ ស្តីពីបរិស្ថានសន្តិសុខក្នុងតំបន់ និងអន្តរជាតិ ជាមួយរដ្ឋមន្ត្រីការពារជាតិអាស៊ាន។

ស្របពេលគ្នានេះដែរ សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងចូលរួមកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុន កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-រុស្ស៊ី និងកិច្ចប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការពារជាតិអាស៊ាន-សហរដ្ឋអាមេរិក។ នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-រុស្ស៊ី **សម្តេចពិជ័យសេនា** នឹងធ្វើការផ្លាស់ប្តូរទស្សនៈ ស្តីពីបញ្ហាប្រឈមសន្តិសុខតំបន់ និងអន្តរជាតិ។

ដោយឡែក នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក **សម្តេចពិជ័យសេនា** នឹងចូលរួមផ្លាស់ប្តូរទស្សនៈ ស្តីពីបរិស្ថានសន្តិសុខតំបន់ និងអន្តរជាតិជាមួយរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក ហើយក៏នឹងអនុម័តសេចក្តីថ្លែងការណ៍រួម ស្តីពីការលើកកម្ពស់ភាពជាដៃគូរសម្រាប់សន្តិសុខប្រកបដោយចីរកាល។

នៅក្នុងពេលនៃកិច្ចប្រជុំខាងលើ **សម្តេចពិជ័យសេនា** ឧបនាយករដ្ឋមន្ត្រី ក៏មានជំនួបទ្វេភាគីជាមួយរដ្ឋមន្ត្រីការពារជាតិនៃបណ្តាប្រទេសអាស៊ានផងដែរ៕

*ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩*

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh